

# ក្រណាត់មួយណា?


Lita Lestianti

Evellyne Andrya



Let's Read

The Asia Foundation



ជិតថ្ងៃត្រង់ហើយ ម៉ែមិនទាន់មកពីផ្សារនៅឡើយ។ សំណាងល្អ មានលោកតា និងលោកយាយនៅផ្ទះ។ បាយូ ជួយលោកយាយ មើលហាងជ្រលក់ក្រណាត់ពណ៌របស់ម៉ែ។ ឌីឌិត ជាប្អូនប្រុស របស់គេ ចាប់ផ្តើមយំកិកកុកពេលលោកយាយកំពុងបី។

”វូមវៈអឺ...!” បាយូ ព្យាយាមបន្លែងជាមួយ ឌីឌិត ប៉ុន្តែគេមិន បាត់យំសោះ។



”ឪឱត ប្រាកដជាយំរកក្រណាត់ដែលគេចូលចិត្តហើយ
លោកយាយ” បាយូ និយាយ។
”អូ! បែបនេះទេតើបានជាគេយំ។ អ៊ីចឹងចៅទៅយកកំណាត់
នោះមក!” លោកយាយតប។



ប៉ុន្តែ បាយូ រកមិនឃើញក្រណាត់នោះនៅក្នុងបន្ទប់សោះ។ តើក្រណាត់នោះនៅឯណាទៅ?

"តើចៅកំពុងរកអ្វី?" លោកតាសួរ។

"តើលោកតាបានឃើញក្រណាត់ដែល ឌីឌិត ចូលចិត្តឬទេ? ក្រណាត់ពណ៌បៃតង" បាយូ តប។



លោកតាឆ្លើយថា គាត់ឃើញមានក្រណាត់បៃតងមួយកំពុង
ហាលនៅខាងក្រោយផ្ទះ។



"មិនមែនក្រណាត់បៃតងមួយនេះទេ លោកតា" បាយូ ឆ្លើយ។
"ហេតុអ្វី? ក្រែងពណ៌បៃតងដូចគ្នាទេតើ" លោកតាឆ្ងល់។



បាយូ ក៏រកមើលនៅក្នុងកំនរសម្លៀកបំពាក់ដែលលោកតាទើប
យកមកពីបោកអ៊ុត។ ក្រណាត់របស់ ឌីឌិត គួរតែនៅក្នុងនេះ។
"នេះក្រណាត់បៃតង! មួយនេះមែនទេ?" លោកតាសួរ។
"មិនមែនពណ៌បៃតងស្រាលបែបនេះទេ" បាយូ ឆ្លើយ។



ប្រហែលជាវានៅក្នុងទូខោអាវហើយមើលទៅ។



លោកតាប្រាប់ ”យកមួយនេះឱ្យគេទៅ វាក៏បៃតងដែរ។”
”មិនមែនពណ៌បៃតងខ្ចីបែបនេះទេ លោកតា។” បាយូ
គ្រវីក្បាល។



ឪឱត នៅតែយំមិនព្រមបាត់។ លោកតា បបួល ឪឱត ទៅក្រៅ
មើលចាប។



លោកយាយជួយ បាយូ រកក្រណាត់នៅក្នុងហាង។
"ប្រហែលជាវាកប់នៅកន្លែងណាមួយពេលយកទៅបោកហើយមើលទៅ។" បាយូ រអ៊ូ។



លោកយាយ ក៏រកឃើញក្រណាត់ពណ៌បៃតងមួយផ្ទាំង។ គាត់សួរ ”តើបៃតងចាស់នេះមែនទេចៅ?”

”ចៅគិតថា មិនមែនមួយនេះទេ។” បាយូ តប។



ឪឱិត យំកាន់តែខ្លាំង។



អូ! តើ ឪឱត ចង្អុលអ្វី?



អូ! នេះហើយក្រណាត់របស់ ឪឱត! គេរកឃើញហើយ!




ឥឡូវ ឪឱត ឈប់យំហើយ។ គេគេងលក់យ៉ាងស្កប់ស្កល់ ហើយម៉ែក៏មកដល់ល្មម!

The Asia Foundation
Improving Lives, Expanding Opportunities

litara
Foundation

រក្សាសិទ្ធឆ្នាំ២០១៩ អង្គការមូលនិធិអាស៊ី
សៀវភៅនេះត្រូវបានផលិតឡើងតាមរយៈសិក្ខាសាលាស្តីពីការផលិតសៀវភៅ ដែលរៀបចំឡើងក្រោមកិច្ចសហការរវាងមូលនិធិ លីតារ៉ា និងអង្គការមូលនិធិអាស៊ី។ សិក្ខាសាលានិងការអភិវឌ្ឍវិជ្ជាជីវៈ រួមជាមួយការកែសម្រួល និងការរចនាសៀវភៅនេះ ត្រូវបានធ្វើឡើងដោយមូលនិធិលីតារ៉ា។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Sing Endi Jarite? (Which Cloth?)*, Author: Lita Lestianti. Illustrator: Evellyne Andrya. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/
Contributing translators: Somey Chheang, Sopheak Thon, and Chou Chinith